**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និង**
**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
លេខ ០២៣ [illegible]/គជប

## សេចក្តីណែនាំរួម

## ស្តីពី

## ការធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងអនុក្រឹត្យលេខ២២ អនក្រ បក. ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការ អំណាច តួនាទី និងភារកិច្ចឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចលេខ១៦៧ គ.ជ.ប ស.ស.រ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧។

ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមវិធានដែលបានចែងក្នុងច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ប្រកបដោយប្រក្រតីភាពក្នុងរយៈពេលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមធ្វើការណែនាំដូចខាងក្រោម៖

### ១. ចំពោះមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

ចាប់ពីពេលបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោត មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំពង្រឹងសាមគ្គីភាព និងសហ

ប្រតិបត្តិការជាមួយគ្នា ដើម្បីបំពេញការងារឱ្យបានត្រឹមត្រូវតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវប្រកាន់ជំហរអព្យាក្រឹត មិនលម្អៀង ក្នុងនោះ ៖

- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិធ្វើសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតដោយស្មើភាពគ្នាដូចបេក្ខជនដទៃទៀត តែមិនត្រូវប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឥទ្ធិពលនៃរដ្ឋបាលឃុំ សង្កាត់ និងមិនត្រូវប្រើប្រាស់មធ្យោបាយ សម្ភារ និងថវិការបស់រដ្ឋបាលឃុំ សង្កាត់ ទៅបម្រើសកម្មភាពរបស់គណបក្សនយោបាយណាមួយ ឬបម្រើសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយឡើយ។

- ដើម្បីធានានិរន្តរភាពការងារក្នុងរដ្ឋបាលឃុំ សង្កាត់ ក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង ត្រូវពិភាក្សាគ្នារៀបចំកម្មវិធីបែងចែកវេនប្រចាំការតាមថ្ងៃនីមួយៗនៅសាលាឃុំ សង្កាត់ ដោយស្មើភាពរវាងមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធានាឲ្យមានសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងតិចចំនួន០១(មួយ)រូបសម្រាប់ប្រចាំការតាមថ្ងៃនីមួយៗ។ លិខិតចាត់តាំងបែងចែកវេនប្រចាំការនេះ ត្រូវថតចម្លង ០១(មួយ) ច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ០១(មួយ)ច្បាប់ ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមី និងត្រូវបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ចំនួន ០១(មួយ)ច្បាប់។

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលខុសត្រូវក្នុងវេនប្រចាំការតាមថ្ងៃនីមួយៗ ត្រូវទទួលសម្របសម្រួលកិច្ចការរដ្ឋបាលឃុំ សង្កាត់ប្រចាំថ្ងៃ ការអភិវឌ្ឍ សំណើ និងសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋរបស់ខ្លួនស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋាននានាសម្រាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានចាត់តាំងឱ្យប្រចាំការ មិនត្រូវចូលរួមក្នុងយុទ្ធនាការឃោសនារបស់គណបក្សនយោបាយណាមួយនៅក្នុងថ្ងៃដែលសាមីខ្លួនត្រូវប្រចាំការនោះឡើយ។ ក្នុងពេលប្រចាំការករណីមានកិច្ចការណាដែលត្រូវសម្រេច និងចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលវេនប្រចាំការនោះ ត្រូវទាក់ទងជាបន្ទាន់ជាមួយមេឃុំ ចៅសង្កាត់ ដើម្បីដោះស្រាយការងារទាំងនោះស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តកំណត់។

- មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យ និងសម្រេចអនុញ្ញាតច្បាប់ឈប់សម្រាកពីការងាររបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ផ្អែកតាមពាក្យសុំច្បាប់របស់សាមីខ្លួនដូចមានគំរូពាក្យសុំភ្ជាប់សេចក្ដីណែនាំនេះ។

**២. ចំពោះស្មៀនឃុំ សង្កាត់**

ស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីរាជការស៊ីវិល ត្រូវមានវត្តមានជាប្រចាំនៅសាលាឃុំ សង្កាត់ នៅរៀងរាល់ថ្ងៃការងារ។

ស្មៀនឃុំ សង្កាត់ ត្រូវប្រកាន់អាកប្បកិរិយាការងារ និងត្រូវយកចិត្តទុកដាក់បំពេញតួនាទី ភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ស្មៀនឃុំ សង្កាត់ ព្រមទាំងបទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត ដូចមន្ត្រីរាជការស៊ីវិលដទៃទៀតដែរ។

**៣. ចំពោះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ**

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមសៀវភៅណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីភារកិច្ចនិងកាតព្វកិច្ចរបស់មេភូមិ និងជំនួយការមេភូមិក្នុងដំណើរការរៀបចំការបោះឆ្នោត ព្រមទាំងត្រូវអនុវត្តតួនាទី និងកាតព្វកិច្ចស្របតាមច្បាប់ បទបញ្ញានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មានសិទ្ធិបញ្ចេញយោបល់ផ្ទាល់ខ្លួន និងមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយដើម្បីគាំទ្រគណបក្សនយោបាយដែលខ្លួនជ្រើសរើស ប៉ុន្តែសកម្មភាពទាំងនោះត្រូវធ្វើក្នុងឋានៈជាបុគ្គលឯកជន គឺមិនមែនក្នុងតួនាទីជាមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិឡើយ។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលមានបំណងចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬជាបេក្ខជន ត្រូវដាក់ពាក្យសុំឈប់សម្រាកការងារទៅមេឃុំ ចៅសង្កាត់សាមី ដើម្បីចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ដូចមានគំរូឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។ ពាក្យសុំច្បាប់ឈប់សម្រាកនេះ ត្រូវថតចម្លង ០១ច្បាប់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងភូមិនីមួយៗ មិនត្រូវស្នើសុំអនុញ្ញាតឈប់សម្រាកពីការងារនៅក្នុងពេលតែមួយជាមួយគ្នា ដោយមិនមានអ្នកប្រចាំការដោះស្រាយការងារសាធារណៈក្នុងភូមិនោះឡើយ។

ក្នុងអំឡុងពេលនៃការឈប់សម្រាកពីការងារដើម្បីចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនមែនជាមន្ត្រីដឹកនាំភូមិឡើយ។

ចំពោះអ្នកដឹកនាំភូមិទាំងឡាយណាដែលមិនបានសុំច្បាប់ឈប់សម្រាកពីការងារ គឺនៅតែជាអ្នកដឹកនាំភូមិតាមឋានានុក្រមដែលត្រូវបម្រើកិច្ចការសាធារណៈក្នុងភូមិប្រកបដោយតម្លាភាព និងត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងក្នុងការបោះឆ្នោត ហើយមន្ត្រីភូមិទាំងនោះមិនត្រូវចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយឡើយ ប្រសិនបើសាមីខ្លួនមិនមានច្បាប់ឈប់សម្រាកពីការងារ។

ទទួលបានសេចក្តីណែនាំរួមនេះ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលខុសត្រូវចាត់ចែងផ្សព្វផ្សាយទូលំទូលាយ និងអនុវត្តសេចក្តីណែនាំរួមនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឃុំ សង្កាត់.......

# ពាក្យសុំច្បាប់ឈប់សម្រាក

ខ្ញុំបាទ/នាងខ្ញុំ..............................ជា....................ភូមិ...................នៃរដ្ឋបាលឃុំឬសង្កាត់ ................. ក្រុង ស្រុក ឬខណ្ឌ.............................. ខេត្តឬរាជធានី.............................។

**សូមគោរពជូន**

**លោក លោកស្រី មេឃុំ ឬ ចៅសង្កាត់**..................................

**កម្មវត្ថុ** ÷ សំណើសុំច្បាប់សម្រាកពីការងារដឹកនាំភូមិរយៈពេល... .ថ្ងៃចាប់ពីថ្ងៃទី......ដល់ថ្ងៃទី.....ខែ... ខែ............. ឆ្នាំ២០១៧។

**យោង** ÷ សេចក្តីណែនាំរួមលេខ...........ស.ណ.ន ចុះថ្ងៃទី.......ខែ ........ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមគោរពជម្រាបជូនលោក លោកស្រី មេឃុំឬចៅសង្កាត់មេត្តាជ្រាបថា ដោយហេតុថា ខ្ញុំបាទ នាងខ្ញុំត្រូវចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរយៈពេល........ថ្ងៃចាប់ពីថ្ងៃទី.......ដល់ថ្ងៃទី........ខែ............ឆ្នាំ២០១៧។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំឬចៅសង្កាត់ មេត្តាអនុញ្ញាតច្បាប់ឲ្យខ្ញុំបាទ នាងខ្ញុំបានឈប់សម្រាកពីការងារដឹកនាំភូមិក្នុងរយៈពេលដូចតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

សូមលោក លោកស្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទឬនាងខ្ញុំ៕

ធ្វើនៅ....................ថ្ងៃទី.........ខែ.............ឆ្នាំ២០១៧

**ហត្ថលេខា និងឈ្មោះសាមីខ្លួន**

បានឃើញនិងឯកភាព

**មេឃុំ ឬ ចៅសង្កាត់**